ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៤ ដោយ អគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## កិច្ចប្រជុំរវាងគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃរដ្ឋសភា (គណៈកម្មការទី២) និងអគ្គនាយកដ្ឋានពន្ធដារ នៅអគ្គនាយកដ្ឋានពន្ធដារ

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៤ នៅអគ្គនាយកដ្ឋានពន្ធដារ បានរៀបចំកិច្ចប្រជុំមួយក្នុងន័យស្វែងយល់សភាពការណ៍ និងការអនុវត្តការងាររបស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតរដ្ឋ **ជាម យៀប** ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម (គណៈកម្មការទី២) នៃរដ្ឋសភា ដោយមានការចូលរួមពីសំណាក់ឯកឧត្តម-លោកជំទាវ ជាសមាជិក-សមាជិកាទាំងអស់នៃគណៈកម្មការទី២ នៃរដ្ឋសភា, ឯកឧត្តម **ជូ វិជិត្ត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងវត្តមានរបស់ឯកឧត្តមអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន-អនុប្រធាននាយកដ្ឋាន ព្រមទាំងវត្តមានរបស់អស់លោក-លោកស្រី ដែលជាប្រធាន-អនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ យ៉ាងច្រើនកុះករ។


រូបភាព៖ ដោយ អគ្គនាយកដ្ឋានពន្ធដារ ឆ្នាំ២០១៤


រូបភាព៖ ដោយ អគ្គនាយកដ្ឋានពន្ធដារ ឆ្នាំ២០១៤


រូបភាព៖ ដោយ អគ្គនាយកដ្ឋានពន្ធដារ ឆ្នាំ២០១៤

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **ជុំ វិជិត្ត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសម្តែងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះគណៈប្រតិភូជាន់ខ្ពស់នៃគណៈកម្មការទីពីរនៃរដ្ឋសភា និងបានធ្វើការកត់សម្គាល់ចំពោះទស្សនកិច្ចផ្លូវការនេះយ៉ាងដូច្នេះថា ÷ ការធ្វើទស្សនកិច្ចមកកាន់អគ្គនាយកដ្ឋានពន្ធដាររបស់គណៈកម្មការទី២ នៃរដ្ឋសភា នាពេលនេះ គឺជាការបំពេញតួនាទីប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ក្នុងឋានៈជាសមាជិកសភា ជាតំណាងរបស់ប្រជារាស្ត្រខ្មែរម្ចាស់ឆ្នោត ដោយបានអញ្ជើញមកទស្សនកិច្ច និងត្រួតពិនិត្យមើលអាគារដែលជាទីស្នាក់ការកណ្តាលរបស់អគ្គនាយកដ្ឋាន ក៏ដូចជាដើម្បីស្វែងយល់និងតាមដានពីការងារប្រមូលចំណូលជូនរដ្ឋ ក្នុងបំណងធ្វើជាមូលដ្ឋានដើម្បីឆ្លើយតបទៅនឹងចម្ងល់របស់ប្រជាពលរដ្ឋនៅតាមមណ្ឌលនីមួយៗ។

ជាការឆ្លើយតប ឯកឧត្តមបណ្ឌិតរដ្ឋ **ជាម យៀប** ប្រធានគណៈកម្មការទី២ នៃរដ្ឋសភា និងជាប្រធានគណៈប្រតិភូ បានសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តមរដ្ឋលេខាធិការ ព្រមទាំងឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងថ្នាក់ដឹកនាំទាំងអស់នៃអគ្គនាយកដ្ឋាន ដែលបានទទួលជួបគណៈប្រតិភូជាន់ខ្ពស់របស់គណៈកម្មការទី២ នៃរដ្ឋសភា ប្រកបដោយកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ នាព្រឹកនេះ។ ឯកឧត្តមបណ្ឌិតរដ្ឋ បានជម្រាបជូនអង្គប្រជុំថា ដំណើរទស្សនកិច្ចនេះគឺជាការស្វែងយល់អំពីដំណើរការនៃការប្រមូលចំណូលពន្ធរបស់អគ្គនាយកដ្ឋាន ក៏ដូចជាទស្សនកិច្ចក្នុងន័យត្រួតពិនិត្យមើលអាគាររបស់អគ្គនាយកដ្ឋាន ពោលគឺមិនមែនជាការមកចាប់ទោសកំហុស ឬស៊ើបអង្កេតអ្វីនោះទេ។ ឯកឧត្តមបណ្ឌិតរដ្ឋបានបន្ថែមទៀតថា យោងតាមមាត្រា៩៦ និង មាត្រា៩៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងយោងតាមជំពូក ៩ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ត្រង់មាត្រា៣៨ និងមាត្រា៣៩ បានចែងអំពីសិទ្ធិគ្រប់បែបយ៉ាងរបស់សមាជិកសភា ក្នុងការកោះអញ្ជើញប្រមុខរាជរដ្ឋាភិបាល និងប្រធានអង្គភាពទាំងឡាយរបស់រាជរដ្ឋាភិបាល ដើម្បីសាកសួរ ឬស្វែងយល់ពីកិច្ចការដែលទាក់ទងនឹងស្ថាប័ននោះ បានគ្រប់ពេលវេលា។ ឯកឧត្តមបណ្ឌិតរដ្ឋបានជម្រាបជូនអង្គប្រជុំបន្ថែមទៀតថា កិច្ចការប្រមូលចំណូលជូនរដ្ឋគឺជាកិច្ចការយ៉ាងលំបាក និងគឺជាអំរែកមួយយ៉ាងធ្ងន់ធ្ងរ ព្រោះថា ការកៀរគរចំណូល និងការធ្វើឲ្យអ្នកជាប់ពន្ធបង់ប្រាក់ពន្ធដោយស្ម័គ្រចិត្ត គឺមិនមែនជាកិច្ចការសាមញ្ញនោះទេ អាចនិយាយបានថា គឺសុទ្ធតែជាកិច្ចការដែលត្រូវយកដើមទ្រូងទៅពាំងគ្រាប់ ក្នុងករណីដែលអ្នកជាប់ពន្ធមិនព្រមបង់ពន្ធ។ រដ្ឋសភាពិតជាមានការយល់ដឹងច្បាស់ណាស់អំពីការលំបាកទាំងអស់នេះ។ ហេតុដូច្នេះ ក្នុងនាម **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** និងក្នុងនាមប្រធានគណៈកម្មការទី២ នៃរដ្ឋសភា ឯកឧត្តមបណ្ឌិតរដ្ឋសូមសម្តែងនូវសមានចិត្តដឹងគុណយ៉ាងជ្រាលជ្រៅ និងសេចក្តីកោតសរសើរយ៉ាងស្មោះស្ម័គ្រ ចំពោះគុណបំណាច់ដ៏ធំធេងរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាពិសេស ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារគ្រប់លំដាប់ថ្នាក់ ដែលបាននិងកំពុងខិតខំបំពេញតួនាទីរបស់ខ្លួនលើកិច្ចការប្រមូលចំណូលជូនរដ្ឋ និងបាននិងកំពុងរួមចំណែករក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលជាកត្តាជំរុញកំណើនសេដ្ឋកិច្ចជាតិ។

ជាកិច្ចបន្ទាប់ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានធ្វើបទបង្ហាញជូនគណៈប្រតិភូជាន់ខ្ពស់នៃគណៈកម្មការទី២ នៃរដ្ឋសភា ដែលទាក់ទងទៅនឹងសមិទ្ធផលសំខាន់នៃកំណែទម្រង់ពន្ធដារ ស្របតាមគោលនយោបាយកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិតរបស់**សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំងជម្រាបជូនពីលទ្ធផលប្រមូលចំណូលពន្ធរបស់អគ្គនាយកដ្ឋាន ក្នុងរយៈពេល០៦ ខែ ដើមឆ្នាំ២០១៤ នេះ។

ដើម្បីរក្សាបាននូវបរិស្ថានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ និងចីរភាពនៃបរិស្ថាន ដែលជាជ្រុងមួយនៃយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ និងដើម្បីឆ្លើយតបនឹងការជំរុញអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំនិងអនុវត្តនូវយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨, បន្តជំរុញការអនុវត្តគោលនយោបាយ បទប្បញ្ញត្តិ និងវិធានការទាំងឡាយដែលមានស្រាប់ ការកែលម្អអភិបាលកិច្ចពន្ធ,ការកែលម្អការផ្តល់សេវាបង់ពន្ធ, ការកែលម្អរដ្ឋបាលសារពើពន្ធ និងការលើកកម្ពស់វប្បធម៌បង់ពន្ធ ដោយឈរលើ

គោលការណ៍ប្រមូលឲ្យអស់លទ្ធភាព សក្តានុពលចំណូលដែលមាននាពេលបច្ចុប្បន្ន ក្នុងបរិបទមិនបង្កើតប្រភេទពន្ធថ្មី និងមិនដំឡើងអត្រាពន្ធ-អាករ លើកលែងតែក្នុងករណីប៉ះប៉ូវដល់ការបាត់ចំណូល និងការគាំពារសុខភាព និងបរិស្ថាន និងធានាបាននូវសមធម៌ក្នុងការបង់ពន្ធ។

ជាងនេះទៅទៀត លទ្ធផលនៃការកែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារ ជាពិសេស ការពង្រឹងការកែលំអរដ្ឋបាលសារពើពន្ធ សំដៅពង្រឹង និងកែលំអសេវាជូនអ្នកជាប់ពន្ធ ក៏ដូចជាសំដៅពង្រឹងសមត្ថភាពផ្ទៃក្នុង និងទំនើបភាវូបនីយកម្មរដ្ឋបាលសារពើពន្ធ បានស្តែងចេញឲ្យឃើញតាមរយៈការធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា (E-Tax) ពោលគឺការគ្រប់គ្រងទិន្នន័យទូទាំងប្រទេសតាមប្រព័ន្ធអេឡិចត្រូនិក (E-Management, E-Filing) ដោយបាននិងកំពុងរៀបចំដាក់ឲ្យដំណើរការ ការចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិក (E-Registration) និងដំណើរការនៃការបង់ប្រាក់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិក (E-Payment) ជាដើម។

ក្នុងបរិបទនៃការកែលម្អគោលនយោបាយសារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងរៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីពន្ធដារ ព្រមទាំងបានរៀបចំបង្កើតនិងបំពេញបន្ថែមរាល់លិខិតបទដ្ឋានគតិយុត្តនានា សំដៅធ្វើឲ្យនីតិវិធីប្រមូលពន្ធប្រព្រឹត្តទៅដោយរលូន ប្រកបដោយតម្លាភាព និងប្រសិទ្ធភាពខ្ពស់ ដែលជាលទ្ធផល ឯកសារបទដ្ឋានគតិយុត្តមួយចំនួនធំ បានបញ្ចប់សព្វគ្រប់ និងបានដាក់ឲ្យអនុវត្តរួចមកហើយដែរ។

ចំណែកឯលទ្ធផលនៃការងារប្រមូលចំណូលពន្ធវិញ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានជម្រាបជូនអង្គប្រជុំ តាមរយៈបទបង្ហាញប្រកបដោយអត្ថន័យ ខ្លឹមសារ និងប្រកបដោយភាពទាក់ទាញពីសំណាក់សមាជិកអង្គប្រជុំយ៉ាងដូច្នេះថា÷ សម្រាប់រយៈពេល ០៦ ខែ ដើមឆ្នាំ២០១៤នេះ អគ្គនាយកដ្ឋានពន្ធដារប្រមូលចំណូលពន្ធ-អាករគ្រប់ប្រភេទ បានចំនួន ២.១២៩.៧៣៨,៥ លានរៀល (គិតជាដុល្លារប្រមាណ ៥៣២,៤៣ លានដុល្លារ) ស្មើនឹង **៥៤%** នៃផែនការច្បាប់ ដែលចំនួននេះ **មានការកើនឡើង ១៣,៥%** នៃលទ្ធផលចំណូលពន្ធប្រចាំឆមាសទី១ ឆ្នាំ២០១៣។ អ្វីដែលកាន់តែមានភាពទាក់ទាញអង្គប្រជុំទៅទៀតនោះ គឺការបង្ហាញពីការកើនឡើងនូវចំណូលពន្ធជាលំដាប់ និងឥតឈប់ឈរពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេស ក្នុងរយៈពេល១០ឆ្នាំ ចុងក្រោយនេះ ពោលគឺកើនឡើងពី ៤៨១.១៨៦ លានរៀល ប្រមាណជា ១២០,៣០ លានដុល្លារ (អនុវត្តបានក្នុងឆ្នាំ២០០៤) រហូតដល់ ៣.៩៧៥.១៦០ លានរៀល (៩៩៣,៧៩លានដុល្លារ) នៅឆ្នាំ២០១៤ (ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤)។

បន្ទាប់ពីបានស្តាប់បទបង្ហាញយ៉ាងក្បោះក្បាយ និងប្រកបដោយខ្លឹមសារយ៉ាងជ្រាលជ្រៅ ក៏ដូចជាការសាកសួរ និងការឆ្លើយតប រវាងគណៈប្រតិភូនៃរដ្ឋសភា និងថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់រួចមក ឯកឧត្តមបណ្ឌិតរដ្ឋ **ជាម យៀប** បានសម្តែងនូវសេចក្តីកោតសរសើរ និងផ្តល់នូវមូលវិចារវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារ។ ឯកឧត្តមបណ្ឌិតរដ្ឋបានជម្រាបជូនអង្គប្រជុំថា នឹងពាំនាំនូវរបាយការណ៍ទាំងនេះជូនប្រមុខដឹកនាំនៃរដ្ឋសភា ព្រមទាំងចងក្រងទុកជារបាយការណ៍ដែលមិនធ្លាប់មាននេះ។

ជាទីបញ្ចប់ឯកឧត្តមបណ្ឌិតរដ្ឋ ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម បានសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ និងសម្តែងនូវសេចក្តីកោតសរសើរជាថ្មីម្តងទៀត ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងថ្នាក់ដឹកនាំរបស់អគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងសមាជិកអង្គប្រជុំទាំងអស់ដែលបានអញ្ជើញចូលរួមប្រជុំនាព្រឹកនេះ និងបានសហការយ៉ាងល្អក្នុងការឆ្លើយតបរាល់សំនួរដែលបានលើកឡើងដោយអ្នកតំណាងរាស្ត្រ។

អង្គប្រជុំបានប្រព្រឹត្តទៅដោយរលូន ប្រកបដោយលទ្ធផលជាផ្លែផ្កា និងបានចប់សព្វគ្រប់នៅវេលាម៉ោងដប់ពីរ នាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសស្និទ្ធស្នាល និងការទទួលខុសត្រូវខ្ពស់។